# មាតិកា

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 23 ខែ 3 ឆ្នាំ 2000

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

២៤-៧-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៧ តែងតាំងឯកឧត្តម ច័ន្ទ នរ៉ា ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ១៤១០

២៨-៧-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៨ តែងតាំងឯកឧត្តម ស្រី ច័ន្ទនី ជាទីប្រឹក្សាឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ១៤១១

២៧-៧-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៩ តែងតាំងលោក ជឿន សុវណ្ណថា ជាឧកញ៉ា ១៤១២

២៧-៧-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៥០ តែងតាំងលោក អ៊ុយ សារ៉ែន ជាឧកញ៉ា ១៤១២

០៣-៨-១៩៩៩ -KRET NS/KRT/0899/151 ACCORDONS le rang
d'Ambassadeur a :
1-S.E MONSIEUR MOUL SAROEUN
2-S.E MONSIEUR NOU DOUM
3-S.E MONSIEUR SO SI NOUN ១៤១៣

## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

២៧-៧-១៩៩៩ -អនុក្រឹត្យលេខ ៦៣ អនក្រ.បក. ស្តីពីការផ្ទេរឥណទាន ១៤១៣

២៩-៧-១៩៩៩ -អនុក្រឹត្យលេខ ៦៤ អនក្រ.បក. ស្តីពីការផ្ទេរឥណទាន ១៤១៥

៣០-៧-១៩៩៩ -អនុក្រឹត្យលេខ ៦៥ អនក្រ.បក. ស្តីពីការបង្កើតគណៈកម្មការតាមដានដំណើរការបែងចែកជំនួយសំរាប់ការងារសង្គមកិច្ច ១៤១៦

៣០-៧-១៩៩៩ -អនុក្រឹត្យលេខ ៦៦ អនក្រ.បក. ស្តីពីការចេញផ្សាយក្រដាសប្រាក់ ១.០០០រៀល ប្រភេទថ្មី ១៤១៨

២៧-៧-១៩៩៩ -អនុក្រឹត្យលេខ ៤៣ អនក្រ.តត. ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤១៩

| | | |
|---|---|---|
| ២៧-៧-១៩៩៩ | -អនុក្រឹត្យលេខ ៤៤៤ អនក្រ.បក. ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២០ |
| ២៧-៧-១៩៩៩ | -អនុក្រឹត្យលេខ ៤៤៥ អនក្រ.បក. ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២១ |
| ២៧-៧-១៩៩៩ | -អនុក្រឹត្យលេខ ៤៤៦ អនក្រ .បក ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២២ |
| ២៧-៧-១៩៩៩ | -អនុក្រឹត្យលេខ ៤៤៧ អនក្រ .បក ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២៣ |
| ២៧-៧-១៩៩៩ | -អនុក្រឹត្យលេខ ៤៤៨ អនក្រ .បក ស្តីពីការជូនមេដាយស្ថាបនាជាតិ | ១៤២៥ |
| ៣០-៧-១៩៩៩ | -អនុក្រឹត្យលេខ ៤៤៩ អនក្រ .បក ស្តីពីការតែងតាំងមន្ត្រីរាជការ | ១៤២៦ |


## ២-សេចក្តីសំរេច


| | | |
|---|---|---|
| ២៤-៧-១៩៩៩ | -សេចក្តីសំរេចលេខ ៥៣ សសរ. ស្តីពីការបង្កើតគណៈបញ្ជាការរៀបចំ និងការពារពិធីកំទេចអាវុធនៅបណ្តាខេត្ត-ក្រុង | ១៤២៧ |


# III- ការងារបណ្តាក្រសួង

## ១-ធនាគារជាតិ នៃកម្ពុជា

### ប្រកាស


| | | |
|---|---|---|
| ២៧-៧-១៩៩៩ | -ប្រកាសលេខ ធ៥៩៩-៨១ ប្រក . ស្តីពីការបញ្ឈប់ផ្តល់ការប្រាក់លើប្រាក់បញ្ញើដល់អតិថិជននៅតាមបណ្តាសាខាធនាគារជាតិ នៃកម្ពុជា | ១៤២៩ |


## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

### ប្រកាស


| | | |
|---|---|---|
| ២៩-៧-១៩៩៩ | -ប្រកាសលេខ ៣២៩ ពណៈគពទ.ប្រក ស្តីពីវិធានការចំពោះផលិតផលម្ហូបអាហារ ដែលមានផ្លាកសញ្ញាពុំសមស្របតាមបទប្បញ្ញត្តិជាធរមាន | ១៤៣០ |

# I. ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៧

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសបង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រមុខរដ្ឋស្តីទី ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១.- តែងតាំងឯកឧត្តម ចន្ទ នារ៉ា ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ទទួលបន្ទុកការងារនយោបាយ សេដ្ឋកិច្ច មហាផ្ទៃ និងការពារជាតិ មានឋានៈស្មើនឹងរដ្ឋលេខាធិការ ជំនួសឯកឧត្តម នូ សុវណ្ណារ៉ា ដែលត្រូវផ្លាស់ចេញ ។

មាត្រា ២.- ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣.- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ធ្វើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើ ឲ្យប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយ នៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ១៩៩៩
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ១៩៩៩ ដែលប្រកាសបង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- យោងតាមសំណើរបស់ប្រមុខរដ្ឋស្តីទី ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៩

## ត្រាស់បង្គាប់

**មាត្រា ១.-** តែងតាំងឯកឧត្តម ស្រី ចន្ទនី ជាទីប្រឹក្សាផ្ទាល់ឯកឧត្តម ញឹក ប៊ុនឆៃ អនុប្រធានទី២ នៃព្រឹទ្ធសភា ទទួលបន្ទុកពាណិជ្ជកម្ម ឧស្សាហកម្ម និងគមនាគមន៍ មានឋានៈស្មើនឹង អនុរដ្ឋលេខាធិការ ។

**មាត្រា ២.-** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ធ្វើនៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ជឿន សុវណ្ណថា

ជា

ឧកញ៉ា

ធ្វើនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៥០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក អ៊ុយ សារិន

ជា

ឧកញ៉ា

ធ្វើនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

KRET NS/KRT/0899/151
NOUS
NORODOM SIHANOUK
Roi du Cambodge

ACCORDONS

le rang d'Ambasadeur à :

1-S.E Monsieur MOUL SAROEUN
2-S.E Monsieur NOU DOUM
3-S.E Monsieur SO SINUON

Fait le 03 Aôut 1999
Signé
NORODOM SIHANOUK

----

# II. រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ៦៣ អនក្រ .បក
### ស្តីពីការផ្ទេរឥណទាន

------

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨អត្រ្គិ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពី ការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំពោះ និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

មាត្រា ១.- ត្រូវបានអនុញ្ញាតិ ឲ្យផ្ទេរឥណទានថវិកា ចំនួន ១.៤៧០លានរៀល (មួយពាន់ បួនរយចិតសិបលានរៀល) ពីជំពូក៩១ (ចំណាយឥតគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) របស់ក្រសួងអប់រំយុវជន និងកីឡា ផ្នែកអប់រំ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

មាត្រា ២.- ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតិឲ្យប្រើប្រាស់ សំរាប់ទូទាត់ថ្លៃបោះពុម្ពសៀវភៅអក្ខរកម្ម ឆ្នាំ ១៩៩៨ សងឲ្យក្រុមហ៊ុន សំបូរ វុទ្ធី និង ជីវ ឡេង ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និងត្រា

**គាត ឈន់**

★★★

# អនុក្រឹត្យលេខ ៦៤ អនក្រ.បក
## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រម នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៦ អនក្រ .បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ .បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១.-** ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៣០០លានរៀល (បីរយលានរៀល) ពីជំពូក៤១ (ចំណាយឥតគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក១០

(បៀវត្ស និងប្រាក់បំណាច់) ចំនួន ៥លានរៀល (ប្រាំលានរៀលគត់) និងជំពូក១១ (ចំណាយដំណើរការរដ្ឋបាលសំភារៈ និងជួសជុលតូច) ចំនួន២៩៥លានរៀល (ពីររយកៅសិបប្រាំលានរៀលគត់) របស់ក្រសួងបរិស្ថាន សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

មាត្រា ២.- ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតិឲ្យប្រើប្រាស់ សំរាប់បើកប្រាក់បៀវត្សជូនមន្ត្រីរាជការ និងចំណាយដំណើរការរដ្ឋបាល ដែលខ្វះក្នុងឆ្នាំ ១៩៩៩ ។

មាត្រា ៣.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខា និងត្រា
**គាត ឈន់**

***

## អនុក្រឹត្យលេខ ៦៥ អនក្រ.បក

## ស្តីពីការបង្កើតគណៈកម្មការតាមដានដំណើរការ
## បែងចែកជំនួយសំរាប់ការងារសង្គមកិច្ច

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- ផ្អែកលើការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**មាត្រា ១.-** បង្កើតគណៈកម្មការតាមដានដំណើរការបែងចែកជំនួយ ដែលបានមកពីប្រទេស និង ស្ថាប័នអន្តរជាតិ ម្ចាស់អំណោយនានាសំរាប់ការងារសង្គមកិច្ច ។

**មាត្រា ២.-** គណៈកម្មការនេះ មានសមាសភាព ដូចតទៅ :

| | | |
|---|---|---|
| ១- ឯកឧត្តម ឆាយ ថន | រដ្ឋមន្ត្រីក្រសួងផែនការ | ជាប្រធាន |
| ២- ឯកឧត្តម គង់ វិបុល | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម អ៊ឹម សិទ្ធី | រដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា | ជាសមាជិក |
| ៤- ឯកឧត្តម នឹម ថូត | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ជាសមាជិក |
| ៥- ឯកឧត្តមម៉ម ប៊ុនហេង | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ជាសមាជិក |
| ៦- លោកជំទាវ អ៊ឹង គន្ធាផាវី | រដ្ឋលេខាធិការក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| ៧- ឯកឧត្តម លី ធុច | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |

**មាត្រា ៣.-** គណៈកម្មការខាងលើមានភារកិច្ច ដូចតទៅ :

- តាមដានរាល់សកម្មភាពបែងចែកជំនួយរបស់ប្រទេស និងស្ថាប័នអន្តរជាតិ ម្ចាស់អំណោយនានា សំរាប់ការងារសង្គមកិច្ចក្នុងគោលបំណងធានាឲ្យបាននូវការបែងចែកឲ្យចំគោលដៅ និងការប្រើប្រាស់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីបង្កើននូវជំនឿជឿជាក់ពីប្រទេសផ្តល់ជំនួយ ។
- វិភាគអំពីសមាមាត្រ នៃការបែងចែកឲ្យបានសមស្របតាមវិស័យការងារ ភារកិច្ច
- ប្រៀបធៀបសមាមាត្រ នៃការចំណាយរវាងសេដ្ឋកិច្ច យោធា នគរបាល និងការចំណាយផ្នែកសង្គមកិច្ចលើផ្នែកផ្សេងទៀត នៃថវិកាជាតិសំដៅឲ្យមានការចំណាយយ៉ាងសមស្របទៅលើផ្នែកសង្គមកិច្ច
- ចូលរួមប្រជុំការងារឲ្យបានសកម្មតាមការអញ្ជើញ របស់គណៈកម្មការសំដៅវិភាគផ្លូវប្រសិទ្ធភាពទប់ស្កាត់រាល់ភាពអសកម្មក្នុងការបែងចែក
- តាមដានការអភិវឌ្ឍន៍ នៃការចំណាយផ្នែកសង្គមកិច្ច

- ធ្វើរបាយការណ៍ ស្តីពីសកម្មភាពការងាររបស់គណៈកម្មការជូននាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលតាមកាលបរិច្ឆេទ ដែលបានកំណត់ក្នុងរបបរាយការណ៍ ។

មាត្រា ៤.- អនុក្រឹត្យនេះ ចូលជាធរមានបញ្ញត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

មាត្រា ៥.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ព្រមទាំងស្ថាប័ន ដែលពាក់ព័ន្ធ និងលោកជំទាវ ឯកឧត្តមដែលមាននាមចែងក្នុងមាត្រា២ ខាងលើ ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធិភាព ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៦៦ អនក្រ .បក**

**ស្តីពីការចេញផ្សាយក្រដាសប្រាក់ ១.០០០រៀល ប្រភេទថ្មី**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី____ខែ____ឆ្នាំ____

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃធនាគារជាតិ នៃកម្ពុជា
- តាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា

**សំរេច**

មាត្រា ១.- អនុញ្ញាតឲ្យចេញផ្សាយ ធ្វើចរាចរ និងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវក្រដាសប្រាក់ ១.០០០រៀល ប្រភេទថ្មី ទន្ទឹមនឹងប្រភេទប្រាក់ ដែលមានចេញផ្សាយរួចមកហើយ ។

**មាត្រា ២.-** ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាសមួយ ដើម្បីផ្សព្វផ្សាយពីលក្ខណៈពិសេស នៃក្រដាសប្រាក់ប្រភេទថ្មីនេះ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន និងអភិបាលខេត្ត-ក្រុង ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យលេខ ៤៤៣ អនក្រ .តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

**សំរេច**

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក Mario Ferrucci អតីតអគ្គនាយកទទួលបន្ទុកជំនួយសំរាប់កម្ពុជា នៃសហគមន៍អឺរ៉ុប ដែលបានបរិច្ចាគនូវកំលាំង

កាយ ចិត្ត ខិតខំ ស្វែងរកជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ សំរាប់ការស្តារ និងអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា លើគ្រប់វិស័យ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្ត អនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៨៤៨ អនក្រ .តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរ ដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សំរេច

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនឯកឧត្តម Masaki Saito ឯកអគ្គរាជទូត ជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានបរិច្ចាគនូវកំលាំងកាយ ចិត្ត ខិតខំ ស្វែង រកជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ សំរាប់ការស្តារ និងអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា លើគ្រប់វិស័យ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៨៤៥ អនក្រ.តត
## ស្តីពីការជូនមេដាយស្ហាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## សំរេច

មាត្រា ១.- ត្រូវបានប្រគល់ **មេដាយមាសស្ហាបនាជាតិ** ជូនលោក Ambassador Michel Caillouet ប្រធានគណៈប្រតិភូសហគមន៍ អឺរ៉ុប ទទួលបន្ទុកជំនួយសំរាប់បោះឆ្នោតឆ្នាំ ១៩៩៨ នៅកម្ពុជា ដែលបានបរិច្ចាគនូវកំលាំងកាយ ចិត្ត ខិតខំ ស្វែងរកជំនួយដ៏ច្រើនសន្ធឹកសន្ធាប់ សំរាប់ការស្តារ និងអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជាលើគ្រប់វិស័យ ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

## អនុក្រឹត្យលេខ ៤៤៦ អនក្រ .តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

-----

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

## សំរេច

**មាត្រា ១.-** ត្រូវបានប្រគល់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ដែលបានបរិច្ចាគថវិកាជួយកសាងសមិទ្ធផលសាធារណៈនានា ដើម្បីជាប្រយោជន៍ដល់ជាតិ និងព្រះពុទ្ធសាសនានៅក្នុងទឹកដីខេត្តកំពង់ចាមដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១- អង្គការ មូលនិធិសង្គ្រោះកុមារ អូស្ត្រាលី | | | |
| ២- ព្រះតេជគុណ | ញ៉ែម កែវ | ទឹកប្រាក់ | ១២៧.២៥០.០០០រៀល |
| ៣- ព្រះតេជគុណ | ស៊ាន លាន | ទឹកប្រាក់ | ១២៥.០០០.០០០រៀល |
| ៤- ព្រះតេជគុណ | ដេត សឿន | ទឹកប្រាក់ | ១១០.៨៩០.០០០រៀល |
| ៥- ព្រះតេជគុណ | ឃុត សារ៉ | ទឹកប្រាក់ | ៧៥.០០០.០០០រៀល |
| ៦- ឯកឧត្តម | ជៀង អំ | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៧- លោកឧកញ៉ា | ម៉ក់ គឹមហុង | ទឹកប្រាក់ | ២៧.០០០ដុល្លារអាមេរិក |
| ៨- លោក | លឹម ស៊ុនលាង | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៩- លោក | សុខ សាម | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ១០- លោក | ជៀម មីសេរ | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |

| | | | |
|---|---|---|---|
| ១១- លោក | ឡាន សាលី | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

| | | |
|---|---|---|
| ១- លោក ជាន់ ឈឹម | ទឹកប្រាក់ | ២១.០០០.០០០រៀល |
| ២- លោក ច្រឹង គឹមស្រ៊ាង | ទឹកប្រាក់ | ២០.០០០.០០០រៀល |
| ៣- លោក អ៊ាត គីមលាង | ទឹកប្រាក់ | ២៣.០០០.០០០រៀល |

គ-មេដាយសំរិទ្ធស្ថាបនាជាតិ :

| | | |
|---|---|---|
| ១- លោកស្រី KAREN HIL | ទឹកប្រាក់ | ២.០០០ដុល្លារអាមេរិក |
| ២- លោក អ៊ឹម យ៉ុន | ទឹកប្រាក់ | ១៣.៦០០.០០០រៀល |
| ៣- លោក ស៊ិន សុខុន | ទឹកប្រាក់ | ១៣.២៥០.០០០រៀល |
| ៤- លោក ទ្រី ផាន្នី | ទឹកប្រាក់ | ១២.១៥០.០០០រៀល |

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សាមីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត ក៏ពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៤៤៧ អនក្រ .តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

-----

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត ស្វាយរៀង

**សំរេច**

មាត្រា ១.- ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ១៣រូប ដែលបានបរិច្ចាគថវិកា ជួយកសាងសមិទ្ធផលនានានៅក្នុងទីរួមខេត្ត ស្វាយរៀង ដូចមានរាយព្រះនាម និងទឹកប្រាក់ខាងក្រោមនេះ :

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១- ឯកឧត្តម ហុក ឡុងឌី | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ២- លោក គឹម ឆា | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៣- លោក ប៊ុន សារ៉ាន់ | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៤- លោក តិម សោភ័ណ្ឌរ័ត្ន | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៥- លោក រស់ ឆាយ | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៦- លោក ពុត សយ | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៧- លោក ថាច់ រតនា | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៨- លោក ហ៊ូ រតនះ | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ៩- លោក ជុំ ហាត | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |
| ១០- លោក សោម សាន | ទឹកប្រាក់ | ១០.០០០ដុល្លារអាមេរិក |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១- លោកទ៊ីវ សារ៉េន | ទឹកប្រាក់ | ៥.០០០ដុល្លារអាមេរិក |
| ២- លោក នួន សុន | ទឹកប្រាក់ | ៥.០០០ដុល្លារអាមេរិក |
| ៣- លោក ឡាំ ប៊ុនស៊ីយ | ទឹកប្រាក់ | ៥.០០០ដុល្លារអាមេរិក |

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្ត ស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៤៨៨ អនក្រ.តត

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

-----

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

### សំរេច

**មាត្រា ១.-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនខ្មែរ និងកូរ៉េ ដែលបានជួយអភិវឌ្ឍន៍កងពលតូច ទ័ពពិសេសឆ័ត្រយោងលេខ ៩១១ ដូចជាជួយកសាងបន្ទាយផ្គត់ផ្គង់សំភារៈហ្វឹកហាត់ និងជួយហ្វឹកហ្វឺនបច្ចេកទេសឆ័ត្រយោង ។ល។ ដែលចំណាយថវិកាអំណោយសរុបប្រមាណជិតមួយពាន់ដុល្លារអាមេរិក ដូចមានរាយនាម ខាងក្រោមនេះ :

១- នាយឧត្ដមសេនីយ៍ កែ គឹមយ៉ាន

២- ឧត្ដមសេនីយ៍ឯក ហុក ឡុងឌី

៣- ឧត្ដមសេនីយ៍ត្រី ចាប ឥត្ថី

៤- លោក ជុន យុងម៉ាន់

៥- លោក ប៉ាកយ៉ុងចា

៦- លោក ស៊ី សាំងស៊ីន

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

# អនុក្រឹត្យលេខ ៤៤៩ អនក្រ .តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

-----

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

## សំរេច

មាត្រា ១.- តែងតាំងលោក **ស៊ា គុសល** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល ជាប្រធាននាយកដ្ឋានច្បាប់ និងកុងស៊ុល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជំនួសលោក **ហាទ ម៉ុនសេ** ដែលត្រូវបានតែងតាំងជាជំនួយការសម្តេចនាយករដ្ឋមន្ត្រី ។

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិ-ការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## ២- សេចក្តីសំរេច

ភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ៥៣ សសរ.

### ស្តីពីការបង្កើតគណៈបញ្ជាការរៀបចំ និងការពារ

### ពិធីកំទេចអាវុធ នៅបណ្តាខេត្ត-ក្រុង

-----

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ៣៨ អនក្រ .បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការទិញ-ដូរ ការកែកញ្ចប់ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ
- បានឃើញ សេចក្តីសំរេចលេខ ២៨ សសរ. ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មការដកហូតអាវុធជាតិផ្ទុះគ្រប់ប្រភេទ
- ពិនិត្យសំណូមពរចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១:** ត្រូវបានបង្កើតគណៈបញ្ជាការរៀបចំ និងការពារពិធីកំទេចអាវុធ និងបណ្តាខេត្ត-ក្រុង រួមមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម ឯម សំអាន | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម អភិបាលខេត្ត-ក្រុង | | អនុប្រធាន |
| ៣- ឯកឧត្តម មេបញ្ជាការយោធភូមិភាគ | | សមាជិក |
| ៤- ឯកឧត្តម ខ្វាន់ សៀម | មេបញ្ជាការកងរិស្វកម្ម ក.ឃ.ខ.ភ | សមាជិក |

| | | |
|---|---|---|
| ៥- ឯកឧត្តម ហ៊ុន ស៊ុយ | អនុរដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- ឯកឧត្តម យូ ស៊ុនឡុង | ប្រធាននាយកដ្ឋានកណ្ដាលសន្តិសុខ | សមាជិក |
| ៧- លោក ឧ.យុន ឈុនី | អនុប្រធាននាយកដ្ឋានកណ្ដាលសណ្ដាប់ធ្នាប់ | សមាជិក |
| ៨- លោក ឧ.ម៉ៅ ចន្ទតារា | ប្រធានសេនាធិការអគ្គនាយកដ្ឋាននគរបាលជាតិ | សមាជិក |
| ៩- លោក ឧ.អ៊ុក គឹមលេខ | ប្រធាននាយកដ្ឋាននគរបាលរដ្ឋបាល | សមាជិក |
| ១០- លោក ឧ.សុខ ផល | ប្រធាននាយកដ្ឋានព័ត៌មានឬទៅ | សមាជិក |
| ១១- លោក ឧ.អ៊ុន ឈន | ប្រធាននាយកដ្ឋានពេទ្យនគរបាល | សមាជិក |
| ១២- លោក ហ៊ុល ដានី | ប្រធាននាយកដ្ឋានពិធីការ | សមាជិក |
| ១៣- លោក ជា សុខុម | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី សរខេង | សមាជិក |
| ១៤- លោក យ៉ារ៉េ គីសិដ្ឋ | | សមាជិក |
| ១៥- លោក មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត-ក្រុង | | សមាជិក |
| ១៦- លោក មេបញ្ជាការកងរាជអាវុធហត្ថខេត្ត-ក្រុង | | សមាជិក |
| ១៧- លោក ស្នងការនគរបាលខេត្ត-ក្រុង | | សមាជិក |

ប្រការ ២ : គណៈបញ្ជាការរៀបចំ និងការពារពិធីកំទេចអាវុធ មានភារកិច្ច ដូចតទៅ :

- រៀបចំចាត់ចែងឲ្យបានសមរម្យ ការពារសុវត្ថិភាពដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និងមហាជនចូលរួម ។
- ត្រួតពិនិត្យកុំឲ្យមានគ្រាប់រំសេវសល់ក្នុងអាវុធ ដែលត្រូវកំទេច រក្សាការពារ និងដឹកជញ្ជូនអាវុធ ដែលកំទេចទៅដល់កន្លែងប្រារព្ធពិធី ។
- ចាត់ចែងអញ្ជើញ និងដោះស្រាយមធ្យោបាយដឹកជញ្ជូនភ្ញៀវ កិត្តិយសជាតិ និងអន្តរជាតិ ពីភ្នំពេញទៅកាន់កន្លែងប្រារព្ធពិធី
- រៀបចំសណ្ដាប់ធ្នាប់សាធារណៈ ចរាចរទាំងនៅក្នុង និងក្រៅបរិវេណកន្លែងប្រារព្ធពិធី
- ការពារសុវត្ថិភាព បង្ការទប់ស្កាត់ និងបង្ក្រាបទាន់ពេលវេលារាល់សកម្មភាពភេរវកម្ម ការបង្កចលាចលផ្សេងៗដល់ថ្នាក់ដឹកនាំជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សិស្ស និស្សិត និងមហាជនចូលរួម ។

ប្រការ ៣ : ក្នុងករណីចាំបាច់គណៈបញ្ជាការមានសិទ្ធិបង្កើតអនុគណៈបញ្ជាការ ដើម្បីជួយក្នុងការងារនេះ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការ ក.ភ.ខ.ភ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ គណៈបញ្ជាការឯកភាពខេត្ត-ក្រុង និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ជាស្ថាពរ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សខេង

***

# III- ការងារបណ្តាក្រសួង

## ១- ធនាគារជាតិ នៃកម្ពុជា

### ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ធ៥៩៩-៨១ ប្រក.**

**ស្តីពីការបញ្ឈប់ផ្តល់ការប្រាក់លើប្រាក់បញ្ញើជាលំអតិថិជន**

**នៅតាមបណ្តាសាខាធនាគារជាតិ នៃកម្ពុជា**

**ទេសាភិបាលធនាគារជាតិ នៃកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃធនាគារជាតិ នៃកម្ពុជា ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦
- បានឃើញ ព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៩៥ ចុះថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា

- យោងតាមសំណើរបស់អគ្គនាយកដ្ឋាន

**សំរេច**

ប្រការ ១: បញ្ឈប់ការផ្តល់ការប្រាក់បញ្ញើជូនគ្រប់អតិថិជន ដែលបានដាក់ផ្ញើនៅសាខាធនាគារជាតិនៃកម្ពុជា នៅតាមខេត្ត-ក្រុងនានា ពីព្រោះសាខាទាំងនោះ ពុំបានការអនុញ្ញាតឲ្យធ្វើអន្តរការីហេកម្មធនាគារដូចធនាគារពាណិជ្ជទៅទៀតឡើយ ។

ចំពោះប្រាក់បញ្ញើ ដែលកំពុងមានសមតុល្យក្នុងគណនី ត្រូវគិតការប្រាក់ជូនត្រឹមថ្ងៃកាលកំណត់ (បីខែ) ដែលបានព្រមព្រៀងគ្នា ។

ប្រការ ២: ដើម្បីជួយលើករក្សាសុវត្ថិភាពដល់ប្រាក់កាសរបស់រដ្ឋ អង្គការជាតិ និងអន្តរជាតិនានា សាខាធនាគារជាតិ នៃកម្ពុជា នៅតាមខេត្ត-ក្រុង អាចជួយទទួល និងរក្សាទុក ដោយពុំផ្តល់នូវការប្រាក់ឡើយ ។

ប្រការ ៣: ប្រកាសលេខ ធ៥ ៩៨-៤៣ ប្រក . ស្តីពីការកំណត់អត្រាការប្រាក់បញ្ញើ សំរាប់សាខាធនាគារជាតិខេត្ត-ក្រុង អនុវត្តជាមួយអតិថិជន ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤: អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន និងគ្រប់នាយកដ្ឋាន អង្គភាពក្រោមឱវាទធនាគារជាតិ នៃកម្ពុជា ព្រមទាំងគ្រប់សាខាធនាគារជាតិ នៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

ទេសាភិបាល

ហត្ថលេខា និងត្រា

ជា ចាន់តូ

***

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៣២៩ ព.ណ.តពន.ប្រក.**

**ស្តីពីវិធានការចំពោះផលិតផលម្ហូបអាហារ**

**ដែលមានផ្លាកសញ្ញាពុំសមស្របតាមបទប្បញ្ញត្តិជាធរមាន**

-----

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញ អនុក្រឹត្យលេខ ៥៤ អនក្រ .បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញ ប្រកាសលេខ ០១២ ពណ.បស.ប្រក . ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរណ៍-អាហរណ៍ និងបង្ក្រាបការក្លែងបន្លំ
- ដើម្បីការពារសុខភាព សុវត្ថិភាពរបស់អ្នកប្រើ និងធានារបៀបរៀបរយក្នុងទីផ្សារ
- យោងទៅលើស្ថានភាពជាក់ស្តែងនាបច្ចុប្បន្ន

សំរេច

ប្រការ ១ : ហាមឃាត់ការនាំចូល ការធ្វើចរាចរ ការលក់ ការដាក់លក់ ការតាំងបង្ហាញនូវ ផលិតផលម្ហូបអាហារ ដែលពុំមានផ្លាកសញ្ញា ឬដែលមានផ្លាកសញ្ញាពុំត្រឹមត្រូវ ឬពុំគ្រប់តាមលក្ខខណ្ឌតំរូវ នៃបទប្បញ្ញត្តិជាធរមាន ដោយពុំគិតនូវគុណភាព ផ្នែកសុខភាព សុវត្ថិភាព នៃសមាសធាតុផ្សំ ។

លក្ខខណ្ឌតំរូវជាធរមាន មានជាអាទិ៍ :

- ឈ្មោះមុខទំនិញ
- ឈ្មោះអាសយដ្ឋានរបស់អ្នកទទួលខុសត្រូវលើផលិតផល (អ្នកផលិត ឬអ្នកវេចខ្ចប់ ឬអ្នកធ្វើពាណិជ្ជកម្ម)
- ប្រភព
- បរិមាណ ទំងន់ ចំណុះ....។ល។
- លេខឡូត៍ និងថ្ងៃផលិត
- ថ្ងៃផុតកំណត់នៃការប្រើប្រាស់
- គ្រឿងផ្សំ
- វិធីប្រើ (ប្រសិនបើចាំបាច់)

- លិខិតអនុញ្ញាតរបស់ស្ថាប័នមានសមត្ថកិច្ចមុនដាក់ឲ្យចរាចរ (បើមានលក្ខខណ្ឌតម្រូវ និងចំពោះផលិតផលផលិតក្នុងស្រុក) ។

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី____ខែ____ឆ្នាំ______

ប្រការ ២ : ហាមឃាត់ការដាក់លក់តាមទីផ្សារ នូវផ្លាកសញ្ញាបោះពុម្ពស្រេច សម្រាប់ផលិតផលម្ហូបអាហារជាក់លាក់ណាមួយ ។

ប្រការ ៣ : រាល់ផលិតផលម្ហូបអាហារដែលធ្វើចរាចរ ឬដាក់តាំងបង្ហាញដោយពុំមានផ្លាកសញ្ញា ឬមានផ្លាកសញ្ញាពុំគ្រប់គ្រាន់ត្រឹមត្រូវតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រការ១ ត្រូវប្រមូលប្រគល់ឲ្យទៅម្ចាស់កម្មសិទ្ធិផលិតផល ដើម្បីឲ្យបំពេញតំរូវតាមបទប្បញ្ញត្តិចំពោះផ្លាកសញ្ញាកាលបើគុណភាព ផ្នែកសុខភាព សុវត្ថិភាព នៃសមាសធាតុផ្សំមានលក្ខណៈសមស្រប ។ ក្នុងករណីផលិតផលម្ហូបអាហារនោះមានគុណភាពពុំសមស្រប ផលិតផលនោះត្រូវប្រមូលកំទេចចោល ឬឲ្យនាំចេញទៅវិញ (ចំពោះទំនិញនាំចូល) ។

ប្រការ ៤ : ម្ចាស់ផលិតផលម្ហូបអាហារ ដែលប្រព្រឹត្តិល្មើសនឹងប្រការ១ ឬប្រការ២ នៃប្រកាសនេះ លើកទី១ ត្រូវបានព្រមានជាលាយលក្ខអក្សរ ។

ក្នុងករណីមិនរាងចាល ហើយប្រព្រឹត្តិជាបន្តទៀត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

ប្រការ ៥ : អគ្គនាយកបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម ប្រធាននាយកដ្ឋានកម្ពុជា ត្រួតពិនិត្យទំនិញនិហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាពដោយសហការជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ។

ប្រការ ៦ : ប្រកាសនេះចូលជាធរមាន ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៩ តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ចម ប្រសិទ្ធ**

★★★